**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជានៅកំពង់ស្ពឺ**
**ថ្ងៃទី៣១ ធ្នូ ២០១៧**
***ជីវិតគ្រួសារដ៏សុខសាន្ត***

អត្ថបទទី១៖ កណ ១៥,១-៦.២១,១-៣
អត្ថបទទី២៖ ហាប ១១,៨.១១-១២.១៧-១៩
ដំណឹងល្អ៖ លក ២,២២-៤០

បងប្អូនជាទីស្រឡាញ់!

នៅពេលបុណ្យណូអែលហើយ ព្រះសហគមន៍ឲ្យយើងមើលគ្រួសារមួយយ៉ាងពិសេស ធ្វើជាគំរូសម្រាប់គ្រួសារយើងទាំងអស់គ្នា។ ថ្ងៃនេះ យើងមានគ្រួសារយ៉ាងពិសេសពីរ គឺគ្រួសារលោកអប្រាហាំ សារ៉ា និងអ៊ីសាក នៅក្នុងសម្ពន្ធមេត្រីចាស់ និងគ្រួសារគំរូពិសេសដ៏កំពូល គឺគ្រួសាររបស់ព្រះយេស៊ូផ្ទាល់ មានព្រះនាងម៉ារី លោកយ៉ូសែបដែលទទួលស្វាគមន៍ព្រះយេស៊ូ។ ដូច្នេះសម្រាប់យើង ពេលយើងមើលឃើញគ្រួសារទាំងពីរហ្នឹងជាគ្រួសារដ៏អស្ចារ្យទាំងពីរ។ ដោយសារ អប្រាហាំនិងសារ៉ា បានទទួលកូនពេលគេមានវ័យចាស់ណាស់ហើយ អប្រាហាំ និងសារ៉ា វ័យ៨0 និងជិត១00ឆ្នាំអស់ហើយ ពេលគេទទួលកូន អ៊ីសាក នេះជាគ្រួសារមួយពិសេស។ អ្វីសំខាន់ គឺយើងស្តាប់ ថាលោកអប្រាហាំបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសារជំនឿរបស់គាត់។

ព្រះជាម្ចាស់បានណែនាំឲ្យគាត់ចេញពីកន្លែងដែលគាត់នៅ ដើម្បីទៅដល់ទឹកដីមួយថ្មី ដែលព្រះជាម្ចាស់ចង់ប្រគល់ឲ្យគាត់។ ការអស្ចារ្យ ដោយសារជំនឿលោកអប្រាហាំ ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកអប្រាហាំពីដើមរៀងមក គាត់ទន្ទឹងរង់ចាំមានកូនជាមួយសារ៉ា ប៉ុន្តែគាត់គ្មានកូនទេ។ ទោះបីសារ៉ាជាស្ត្រីចាស់ និងស្ត្រីអាថែមទៀត មានកូនមិនបាន តែព្រះជាម្ចាស់បានប្រទានកូនឲ្យគាត់ ដោយសារ សារ៉ាមានជំនឿ ។ ដោយសារសារ៉ាជឿលើព្រះជាម្ចាស់ ដូច្នេះមានផ្ទៃពោះដោយសារការអស្ចារ្យពីព្រះជាម្ចាស់ ដោយសារជំនឿរបស់គាត់។ រឿងនេះធ្វើឲ្យយើងពិបាកចិត្តដែរ លោកអប្រាហាំមានកូនតែមួយគត់ ប៉ុន្តែព្រះជាម្ចាស់មានព្រះបន្ទូលថា "**ឥឡូវនេះសូមយកកូននេះ និងសម្លាប់កូននេះ**"។ ដោយសារជំនឿលោកអប្រាហាំធ្វើទៀត ប៉ុន្តែដល់ពេលវាលាត្រូវសម្លាប់កូន ព្រះជាម្ចាស់ថាឈប់ៗ ព្រះជាម្ចាស់បាន សាកលមើល និងល្បងលជំនឿរបស់លោកតាអប្រាហាំ។

ដូច្នេះមេរៀនទី១ ដែលទទួលសម្រាប់ជីវិតរបស់យើងជាគ្រួសារ ដែលយើងមានកូន ឪពុកម្តាយ លោកតាលោកយាយ ក្រុមគ្រួសាររបស់យើងត្រូវការថែរក្សាជំនឿ។ ឲ្យជំនឿលើព្រះជាម្ចាស់ ណែនាំ ឲ្យយើងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើងនៅក្នុងគ្រប់កាលៈទេសៈ ។ លោកតាអប្រាហាំ ពិបាកនឹងសម្លាប់កូនរបស់គាត់ ប៉ុន្តែដោយសារជំនឿគាត់ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយដឹងថា ព្រះជាម្ចាស់មិនចង់ឲ្យយើងពិបាក ព្រះជាម្ចាស់ចង់ឲ្យយើងមានសេចក្តីសុខ។ ព្រះជាម្ចាស់ចង់ឲ្យយើងបង្កើតគ្រួសារដ៏សុខសាន្ត។

ថ្ងៃនេះ យើងមើលព្រះនាងម៉ារី លោកយ៉ូសែប និងព្រះយេស៊ូដែលជាគ្រួសារដ៏សុខសាន្ត ។ ប្រហែលយើងគិតថា យើងធ្វើតាមគេមិនបាន យើងមិនមែនគ្រួសារអស្ចារ្យដូចគេទេ។ គ្រួសារដ៏វិសុទ្ធគឺ ព្រះនាងម៉ារី មិនធម្មតាទេ មិនស្ត្រីចាស់ មិនមែនស្ត្រីអា ប៉ុន្តែព្រះនាងម៉ារីនៅក្មេង និងមានកូនដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ទាំងនៅព្រហ្មចារី ជាការអស្ចារ្យមួយ។ លោកយ៉ូសែប ជាមនុស្សសុចរិតដ៏កំពូល ជាគំរូដ៏ពិសេសសម្រាប់យើងទាំងអស់គ្នា ដូច្នេះក៏មិនស្រួលដែរធ្វើតាមគាត់ ព្រះយេស៊ូជាព្រះជាម្ចាស់ទៀត។ ដូច្នេះ ពេលយើងមើលគ្រួសារដ៏វិសុទ្ធយើងគិតថា នេះមិនមែនសម្រាប់យើងទេ។ ដូច្នេះ គំរូដែលព្រះសហគមន៍ឲ្យយើងមើល យើងគិតថាយើងធ្វើមិនបាន។ ប៉ុន្តែតាមពិតមិនមែនទេ ដោយសារព្រះនាងម៉ារី តាមពិតជាយុវនារីម្នាក់ ដែលបានធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកយ៉ូសែប ក៏ដូចគ្នាដែរគាត់ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គាត់មិនមែនជាមនុស្សពិសេស ប៉ុន្តែគាត់សុខចិត្តរស់នៅ តាមអ្វីដែលព្រះជាម្ចាស់ប្រាប់ដល់គាត់។ ព្រះយេស៊ូបានប្រសូត្រនៅក្នុងរោងសត្វមួយ ក្រោយមកសាបសិបឆ្នាំព្រះយេស៊ូមិនធ្វើអីទេ។ ព្រះយេស៊ូជាទី១កូនង៉ែត ទី២កូនក្មេង ទី៣យុវជន ទី៤ជាមនុស្សពេញវ័យ គាត់រស់នៅក្នុងក្រុមគ្រួសារធម្មតា។ ព្រះយេស៊ូចាប់ផ្តើមរស់នៅជាក្រុមគ្រួសារធម្មតា ដែលទទួលការអប់រំពីឪពុកម្តាយគឺព្រះនាងម៉ារី និងលោកយ៉ូសែប ដែលយកចិត្តទុកដាក់រៀន តាមគម្ពីរធម្មវិន័យ។ នៅថ្ងៃនេះឪពុកម្តាយបានយកកូនមកដល់ព្រះវិហារ ដើម្បីធ្វើពិធីតាមប្រពៃណី។ នៅពេលព្រះយេស៊ូអាយុ១២ឆ្នាំ ព្រះយេស៊ូទៅព្រះវិហារដើម្បីទទួលការអប់រំ និងគាត់អប់រំគេផងដែរ។ ក្រោយមក ព្រះយេស៊ូទទួលជំនាញជាជាងឈើ ឪពុកបង្រៀនកូន ដើម្បីឲ្យចេះកាត់ឈើ ធ្វើតុកៅអីទូ នេះជារបៀបព្រះយេស៊ូរស់នៅក្នុងក្រុមគ្រួសារដ៏វិសុទ្ធ ជាគ្រួសារមួយធម្មតា។

គ្រួសារមួយធម្មតាដែលឪពុកម្តាយ អប់រំកូន ឪពុកម្តាយណែនាំឲ្យកូនរីកចម្រើន ឪពុកម្តាយណែនាំឲ្យកូនស្គាល់ព្រះជាម្ចាស់ ឪពុកម្តាយណែនាំឲ្យកូនមានជំនាញ។ សព្វថ្ងៃ យើងណែនាំកូនយើងឲ្យទៅសាលា យើងណែនាំឲ្យកូនយើងចូលព្រះវិហារ ណែនាំឲ្យកូនយើងចេះអធិដ្ឋាន ណែនាំឲ្យកូនយើងស្តាប់បង្គាប់ឪពុកម្តាយ ណែនាំឲ្យកូនយើងបម្រើឪពុកម្តាយ។ ឪពុកខ្ញុំនិយាយច្រើនដង ខ្ញុំបានបង្កើតកូនដើម្បីឲ្យកូនបម្រើឪពុកម្តាយ។ ពេលខ្ញុំនៅក្មេងគាត់និយាយច្រើនដង ដូច្នេះខ្ញុំធ្វើ ដូចជា លាងចាន បម្រើតុ ធ្វើម្ហូប ដោយសារឪពុកខ្ញុំនិយាយច្រើនដង កូនជាអ្នកបម្រើឪពុកម្តាយ។ ឪពុកម្តាយត្រូវអប់រំ ឲ្យកូនធ្វើជាអ្នកបម្រើ មិនធ្វើតាមចិត្ត។ ដូចព្រះនាងម៉ារី និងលោកយ៉ូសែបអប់រំកូន ដោយកូនស្តាប់បង្គាប់ឪពុកម្តាយ និងដោយឪពុកម្តាយទទួលខុសត្រូវជាន់ខ្ពស់បំផុត ដើម្បីចិញ្ចឹមកូនដើម្បីឲ្យកូនមានសេចក្តីសុខ ដើម្បីឲ្យកូនទៅសាលា ដូច្នេះយើងដឹងថានេះជារបៀបអប់រំកូន។ ជាពិសេស ណែនាំឲ្យគ្រួសាររបស់យើងទៅជាគ្រួសារ មិនមែនចង្អៀតចង្អល់ មិនមែនគ្រួសារដែលចេះតែគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន។

សម្រាប់យើងជាគ្រីស្តបរិស័ទ យើងអប់រំក្រុមគ្រួសាររបស់យើង ដើម្បីឲ្យក្រុមគ្រួសាររបស់យើង ទាំងកូន ទាំងឪពុកម្តាយ ទាំងលោកតាលោកយាយ ទាំងយុវជនក្នុងគ្រួសារចេះមើលដល់បងប្អូនឯទៀតៗ ចេះមើលដល់អ្នកក្រីក្រ ចេះមើលដល់មនុស្សដែលមានទុក្ខលំបាក ចេះមើលដល់គ្រួសារដទៃដែលលំបាក។ ដោយសារមានគ្រួសារខ្លះពិបាក គ្រួសារខ្លះលែងលះគ្នាឈ្លោះគ្នា មានបញ្ហា ហូបស្រា បញ្ហាប្តីរត់ចោលគ្រួសារ ស្ត្រីមេម៉ា មានរឿងច្រើនដែលនាំឲ្យគ្រួសារគ្មានសេចក្តីសុខ។ ដូច្នេះ យើងមានគ្រួសារយើងដែលមានសេចក្តីសុខ យើងធ្វើយ៉ាងមិចចាប់អារម្មណ៍ យកចិត្តទុកដាក់ ដល់គ្រួសារដែលកំពុងមានទុក្ខលំបាក ដែលកំពុងមានការពិបាក នេះជារបៀបដែលយើងត្រូវតែបើកចិត្តគំនិតរបស់យើងបើកក្រុមគ្រួសាររបស់យើង កុំឲ្យទៅជាគ្រួសារមួយចង្អៀតតែឪពុកម្តាយ តាយាយ និងកូនគ្នាយើងដែលគិតរកស៊ីផ្ទាល់ខ្លួន គិតពីសេចក្តីសុខផ្ទាល់ខ្លួន គិតអំពីអំណរសប្បាយផ្ទាល់ខ្លួន គិតតែអំពីកូនផ្ទាល់ខ្លួន ។ ផ្ទុយទៅវិញយើងបើកចិត្តគំនិតដើម្បី ឲ្យគ្រួសារយើងចេះមើលគ្រួសារដែលពិបាក មានច្រើនណាស់។

ដូច្នេះ គ្រួសារដែលមានសមត្ថភាព មានអំណរសប្បាយនិងសេចក្តីសុខ បើកភ្នែកដើម្បីយកចិត្តទុកដាក់ជាមួយគ្រួសារដទៃ ដូចព្រះនាងម៉ារី លោកយ៉ូសែប និងព្រះកុមារ

យេស៊ូ មិនមែនគ្រួសារចង្អៀត។ ខ្ញុំជឿថានៅក្នុងភូមិណាសារ៉ែត ជាជីវិតមួយដែលចេះលើកទឹកចិត្តគ្នា ដែលចេះចាប់អារម្មណ៍ អំពីបងប្អូនឯទៀៗ។ នៅភូមិយើង យើងរស់នៅជាប់គ្នាមែនទែន ដូច្នេះគ្រួសារនីមួយៗយើងស្គាល់គ្នាច្បាស់ណាស់ ពីផ្ទះមួយទៅផ្ទះមួយមានប៉ុន្មានកន្លះម៉ែត្រតែប៉ុណ្ណឹង ដូច្នេះដឹងទាំងអស់ ឈ្លោះគ្នាក៏ដឹង ពេលមានរឿងអន់ចិត្តក៏ដឹង ពេលមានបញ្ហាយើងដឹង ពេលជេគេក៏ដឹង យើងដឹងទាំងអស់។ ដូច្នេះយើងអាចមានសមត្ថភាព ដើម្បីផ្តល់សញ្ញាសំគាល់ នៃសេចក្តីស្រលាញ់ដល់គ្រួសារនានា និងលើកទឹកចិត្តគ្នាដោយសារព្រះសហាគមន៍ជាគ្រួសារមួយយ៉ាងធំ។ យើងរៀនខ្លួន ដែលជាគ្រួសារមួយ ដែលជាមូលដ្ឋាននៃជីវិត នៃសង្គម និងមូលដ្ឋាននៃជីវិតនៅក្នុងភូមិ ។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានក្រុមគ្រួសារដ៏វិសុទ្ធ ដើម្បីឲ្យយើងធ្វើតាម។ ជាពិសេស អធិដ្ឋានសម្រាប់គ្រួសារទាំងអស់ដែលមានទុក្ខលំបាក គ្រួសារដែលមានពិបាក ដើម្បីឲ្យកូនៗអាចរកឃើញសេចក្តីសុខ និងរកឃើញសេចក្តីសង្ឃឹមជានិច្ច ។ សូមព្រះជាម្ចាស់គង់នៅជាមួយយើង ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូត យើងពោរពេញដោយពន្លឺរបស់ព្រះអង្គ។ យើងអរព្រះគុណព្រះអង្គ និងទូលអង្វរព្រះអង្គ ជានិច្ចដើម្បីរកឃើញជីវិត គឺជីវិតគ្រួសារដ៏សុខសាន្ត។ អាម៉ែន៕